ក

មាតិកា

I-ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

២៣-០២-២០០៤	-ព្រះរាជក្រឹត្យ នស/រកត/០២០៤/០៣៨ ស្ដីពីការតែងតាំងឯកឧត្តម ឧត្តមសេនីយ៍ឯក **ទៅ តិរុណា** ជា **ឧកញ៉ា**	៤៨៦
១៥-៣-២០០៤	-ព្រះរាជក្រឹត្យ នស/រកត/០៣០៤/០៤៥ ស្ដីពីការតែងតាំងឯកឧត្តម **យក់ ទ៉ុយ** ជាសាកលវិទ្យាធិការ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច	៤៨៧
១៧-៣-២០០៤	-ព្រះរាជក្រឹត្យ នស/រកត/០៣០៤/០៤៦ ស្ដីពីការតែងតាំងឯកឧត្តម **ជូវ សំគី** ជាសមាជិកក្រុមអ្នកច្បាប់ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ**	៤៨៨
១៧-៣-២០០៤	-ព្រះរាជក្រឹត្យ នស/រកត/០៣០៤/០៤៧ ស្ដីពីការតែងតាំងឯកឧត្តម **សុខ សាយ** ជាទីប្រឹក្សាផ្ទាល់សម្ដេច **ជា ស៊ីម** ប្រធានព្រឹទ្ធសភា ទទួលបន្ទុកការងារអភិវឌ្ឍន៍ជនបទ មានឋានៈស្មើ **រដ្ឋលេខាធិការ** ជំនួសឯកឧត្តម **សំ សាន** ដែលត្រូវផ្លាស់ទៅបំពេញភារកិច្ចថ្មី	៤៨៩
១៧-៣-២០០៤	-ព្រះរាជក្រឹត្យ នស/រកត/០៣០៤/០៤៨ ស្ដីពីការប្រោសព្រះរាជទានចំពោះ ឧកញ៉ា **លី សាយឃាង** នូវគ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ**	៤៩០

II-រាជរដ្ឋាភិបាល

១-អនុក្រឹត្យ

២២-៣-២០០៤	-អនុក្រឹត្យលេខ ០៥ អនក្រ.បក ស្ដីពីការទទួលស្គាល់សាកលវិទ្យាល័យអាយស៊ីអេស	៤៩១
១៥-៣-២០០៤	-អនុក្រឹត្យលេខ ១៤០ អនក្រ.តត ស្ដីពីការតែងតាំងក្រុមប្រឹក្សាភិបាល សហគ្រាសសាធារណៈភ្នាក់ងារកម្ពុជានាវាចរ(កាំសាប)	៤៩៤
១៦-៣-២០០៤	-អនុក្រឹត្យលេខ ១៤១ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ	៤៩៦
១៦-៣-២០០៤	-អនុក្រឹត្យលេខ ១៤២ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ	៤៩៧
១៦-៣-២០០៤	-អនុក្រឹត្យលេខ ១៤៣ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ	៤៩៨
១៦-៣-២០០៤	-អនុក្រឹត្យលេខ ១៤៤ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ	៤៩៩
១៦-៣-២០០៤	-អនុក្រឹត្យលេខ ១៤៥ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ	៥០០

១៧-៣-២០០៤	-អនុក្រឹត្យលេខ ១៤៦ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ	៥០១
២២-៣-២០០៤	-អនុក្រឹត្យលេខ ១៤៧ អនក្រ.តត ស្តីពីការជូនមេដាយការងារ	៥០២
២២-៣-២០០៤	-អនុក្រឹត្យលេខ ១៤៨ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	៥០៣
២២-៣-២០០៤	-អនុក្រឹត្យលេខ ១៤៩ អនក្រ.តត ស្តីពីការតម្លើងឋានន្តរសក្តិនាយនគរបាលជាតិ	៥០៤
២៣-៣-២០០៤	-អនុក្រឹត្យលេខ ១៥០ អនក្រ.តត ស្តីពីការជូនមេដាយការងារ	៥០៥
២៣-៣-២០០៤	-អនុក្រឹត្យលេខ ១៥១ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ	៥០៧
២៣-៣-២០០៤	-អនុក្រឹត្យលេខ ១៥២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	៥០៨
២៣-៣-២០០៤	-អនុក្រឹត្យលេខ ១៥៣ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	៥០៩
២៣-៣-២០០៤	-អនុក្រឹត្យលេខ ១៥៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	៥១០
២៣-៣-២០០៤	-អនុក្រឹត្យលេខ ១៥៥ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	៥១២
២៣-៣-២០០៤	-អនុក្រឹត្យលេខ ១៥៦ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	៥១៣

១_សេចក្តីសំរេច

១៩-៣-២០០៤	-សេចក្តីសំរេច លេខ ១១ សសរ ស្តីពីការរៀបចំកិច្ចប្រជុំនៃក្រុមពិគ្រោះយោបល់ លើកទី ៧	៥១៤
២៣-៣-២០០៤	-សេចក្តីសំរេច លេខ ១២ សសរ ស្តីពីការបង្កើតក្រុមការងារពិសេសអន្តរក្រសួង-ស្ថាប័ន ដើម្បីកែលំអបរិស្ថានវិនិយោគ និងសំរួលពាណិជ្ជកម្ម	៥១៦

II_គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

២៣-៣-២០០៤	-សេចក្តីសំរេចលេខ ០០៣/០៤ គ.ជ.ប ស្តីពីការលុបឈ្មោះបេក្ខជនជាប់ឆ្នោតតំណាងរាស្ត្រ គណបក្ស ប្រជាជនកម្ពុជា ចេញពីមណ្ឌលខេត្ត កំពង់ចាម	៥១៩
២៣-៣-២០០៤	-សេចក្តីប្រកាសលេខ ០០៤/០៤ គ.ជ.ប ស្តីពីការទទួលស្គាល់ឯកឧត្តម **ឌិន គីមស្រេង** តំណាងរាស្ត្រ លំដាប់ទី ៩ របស់គណបក្សប្រជាជនកម្ពុជា នៅមណ្ឌលខេត្ត កំពង់ចាម	៥២០

ព្រះរាជក្រឹត្យ

នស/រកត/០២០៤/០៣៨

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

(បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា)

តែងតាំង

ឯកឧត្តម ឧត្តមសេនីយ៍ឯក ចៅ ភិរុណ

ជា

ឧកញ៉ា

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០០៤
ត្លួងព្រះបរមនាម និង តាមព្រះរាជបន្ទូលបង្គាប់
ប្រមុខរដ្ឋស្តីទី
ហត្ថលេខា និងព្រះរាជលញ្ឆករ
ជា ស៊ីម

លេខៈ ៣៥ ចល

៣៤៧-០៤-០២-០៣៨ ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ មីនា ឆ្នាំ២០០៤
អគ្គលេខាធិការរាជរដ្ឋាភិបាល
ឈាង ទាន់

ព្រះរាជក្រឹត្យ

នស/រកត/០៣០៤/០៤៥

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតនៈ

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតែងតាំងឯកឧត្តម យត់ ខុំយ ជាសាកលវិទ្យាធិការ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។

មាត្រា ២ : សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ អោយបានសំរេច ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៥ ខែ មីនា ឆ្នាំ ២០០៤

ក្នុងព្រះបរមនាមនិងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

លេខៈ ៣៣ ច ល ហត្ថលេខា និងព្រះរាជលញ្ឆករ

ដើម្បីចម្លងចែក ជា ស៊ីម

៣រណ.០៤.០៣.០៤៥

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ៣ ឆ្នាំ២០០៤

អគ្គលេខាធិការរាជរដ្ឋាភិបាល

សុខ ឥាន់

ព្រះរាជក្រឹត្យ

នស/រកត/០៣០៤/០៤៦

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា១.- តែងតាំង ឯកឧត្តម ផុង សំគី ជាសមាជិកក្រុមប្រឹក្សាអ្នកច្បាប់ មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

មាត្រា២.- សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣.- ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០០៤

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

៣រល.០៤.០៣.០៤៦

លេខ: ៣៤ ចល

រួចចំលងចេញពីច្បាប់ដើម

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ២០០៤

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាង តាន់

ព្រះរាជក្រឹត្យ

នស / រកត / ០៣០៤/០៤៧

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និកោរត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ០៨ ខែមីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់អោយប្រើជាផ្លូវការ នូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ១៩៩៩
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៣៩៩/៤៣ ចុះថ្ងៃទី ១១ ខែមីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់តែងតាំង ប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- យោងតាមសំណូមពរចាំបាច់នៃការងារ

ត្រាស់បង្គាប់

មាត្រា១: តែងតាំងឯកឧត្តម ស្វាង សាយ ជាទីប្រឹក្សាសម្តេចផ្ទាល់ ជា ស៊ីម ប្រធានព្រឹទ្ធសភា ទទួលបន្ទុកការងារអភិវឌ្ឍន៍ជនបទ មានឋានៈស្មើ រដ្ឋលេខាធិការ ជំនួសឯកឧត្តម សំ សាន ដែលត្រូវផ្លាស់ទៅបំពេញភារកិច្ចថ្មី ។

មាត្រា២: ប្រធានព្រឹទ្ធសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជាត្រូវទទួលបន្ទុកអនុវត្ត ព្រះរាជក្រឹត្យនេះ។

មាត្រា៣: ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី១៧ ខែ មីនា ឆ្នាំ ២០០៤
ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់
ប្រមុខរដ្ឋស្តីទី
ហត្ថលេខា និងព្រះរាជលញ្ឆករ
ជា ស៊ីម

លេខ: ៣១ ចល
៣/ល.០៤.០៣.០៤៧ ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែមីនា ឆ្នាំ២០០៤
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឧទាំ តាន់

ព្រះរាជក្រឹត្យ

នស/រកត/០៣០៤/០៤៨

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

(បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចប្រមុខរដ្ឋស្តីទី)

ប្រោសព្រះរាជទាន

ចំពោះ

ឧកញ៉ា លី សាយខាង

នូវ

គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី១៧ ខែ មីនា ឆ្នាំ ២០០៤
ក្នុងព្រះបរមនាម និង តាមព្រះរាជបន្ទូលបង្គាប់
ប្រមុខរដ្ឋស្តីទី
ហត្ថលេខា និងព្រះរាជលញ្ឆករ
លេខ: ៣៦២ ច ល
ជា ស៊ីម

៣៩ល-០៤.០៣.០៤៨

ដើម្បីចម្លងចែក
រាជធានីភ្នំពេញ,ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ២០០៤
អគ្គលេខាធិការរាជរដ្ឋាភិបាល

[illegible] តាន់

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ០៨ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការទទួលស្គាល់សាកលវិទ្យាល័យអាយស៊ីអេស

*****

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ស្តីពី ការបង្កើត ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក. ចុះថ្ងៃទី ២៣ ខែមិនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ. ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពី ការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខណៈវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញលិខិតស្នើសុំ របស់លោកស្រី ឃួន សុដារី ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០០៤
- បានឃើញយោបល់ របស់ក្រសួងអប់រំ យុវជន និងកីឡា

ស ម្រ េ ច

មាត្រា ១.: ទទួលស្គាល់គ្រឹះស្ថានឧត្តមសិក្សាឯកជនមួយ ដែលមានឈ្មោះថា **សាកលវិទ្យាល័យអាយស៊ីអេស** " **ICS University** " ហៅកាត់ជាភាសាខ្មែរ " ស.អ.ស.អ. " និង ហៅកាត់ជាភាសាអង់គ្លេស

" I.C.S.U." ។ សាកលវិទ្យាល័យនេះ មានទីតាំងគោលស្ថិតនៅ អាគារលេខ ១៨ ផ្លូវលេខ ២១៤ សង្កាត់បឹងរាំង ខណ្ឌ ដូនពេញ រាជធានីភ្នំពេញ ។

មាត្រា ២ : សាកលវិទ្យាល័យអាយស៊ីអេស ស្ថិតនៅក្រោមឱវាទ របស់ក្រសួងអប់រំ យុវជន និងកីឡា ។

មាត្រា ៣ : សាកលវិទ្យាល័យអាយស៊ីអេស ធ្វើការបណ្តុះបណ្តាល :

- ជំនាញបច្ចេកទេសរយៈពេលខ្លី ។
- ថ្នាក់ បរិញ្ញាប័ត្ររង សិក្សារយៈពេល ២ ឆ្នាំ ជាមធ្យម ។
- ថ្នាក់ បរិញ្ញាប័ត្រ សិក្សារយៈពេល ៤ ឆ្នាំ ជាមធ្យម ។
- ថ្នាក់ ម៉ាស្ទ័រ សិក្សារយៈពេល ២ ឆ្នាំ ជាមធ្យម ។
- ថ្នាក់ បណ្ឌិត សិក្សាស្រាវជ្រាវ រយៈពេលយ៉ាងតិច ៣ ឆ្នាំ ។

សាកលវិទ្យាល័យអាយស៊ីអេស ត្រូវរៀបចំកម្មវិធីសិក្សាលំអិត ដើម្បីសុំការឯកភាពពីក្រសួងអប់រំ យុវជន និងកីឡា ។

មាត្រា ៤ : សាកលវិទ្យាល័យអាយស៊ីអេស មានមហាវិទ្យាល័យចំនួន ០៦ និង វិទ្យាស្ថានបណ្តុះបណ្តាលបច្ចេកទេសមួយ :

- មហាវិទ្យាល័យ មនុស្សសាស្ត្រ និង ភាសាបរទេស
- មហាវិទ្យាល័យ វិទ្យាសាស្ត្រ និង បច្ចេកវិទ្យា
- មហាវិទ្យាល័យសង្គមសាស្ត្រ និង នីតិសាស្ត្រ
- មហាវិទ្យាល័យ គ្រប់គ្រងពាណិជ្ជសាស្ត្រ
- មហាវិទ្យាល័យអប់រំ និង ទេសចរណ៍
- មហាវិទ្យាល័យកសិកម្ម
- វិទ្យាស្ថានបណ្តុះបណ្តាលបច្ចេកទេស ។

ទៅអនាគត សាកលវិទ្យាល័យនេះ អាចបើកមហាវិទ្យាល័យ សាខា ឯកទេស ឬ ប្រភេទបណ្តុះ-បណ្តាលដទៃទៀត ដោយរៀបចំសំណុំបែបបទ សុំការអនុញ្ញាតពីក្រសួងអប់រំ យុវជន និងកីឡា ។

មាត្រា ៥ : សាកលវិទ្យាល័យអាយស៊ីអេស មានក្រុមប្រឹក្សាភិបាលមួយ ដើម្បីពិនិត្យ និងសំរេចលើគោល-នយោបាយ ផែនការអភិវឌ្ឍ អនុម័តលើកម្មវិធីសិក្សា និងការងារបច្ចេកទេសពាក់ព័ន្ធដទៃទៀត ។

មាត្រា ៦ : សាកលវិទ្យាល័យអាយស៊ីអេស ត្រូវគោរពតាមបទដ្ឋានរបស់ក្រសួងអប់រំ យុវជន និងកីឡា ក្នុងការទទួលសិស្ស-និស្សិត ឱ្យចូលរៀន ។

មាត្រា ៧ : សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យអាយស៊ីអេស មានភារកិច្ច :

- ទទួលខុសត្រូវនៅចំពោះមុខច្បាប់ ក្នុងការគ្រប់គ្រងសាកលវិទ្យាល័យ ។
- ជ្រើសរើសសិស្ស-និស្សិតឱ្យចូលរៀន ជ្រើសរើសសាស្ត្រាចារ្យមកបង្រៀន និង បុគ្គលិកមកបំរើការងារ ។

- គ្រប់គ្រងឱ្យបានល្អ នូវការងារបណ្តុះបណ្តាល ការងារស្រាវជ្រាវ ការប្រលង និងការប្រគល់សញ្ញាប័ត្រ ។
- គោរព និង អនុវត្តតាមច្បាប់ និង បទដ្ឋានណែនាំ របស់ក្រសួងអប់រំ យុវជន និងកីឡា និង រាជរដ្ឋាភិបាល ។
- ធានាឱ្យបាន នូវសុវត្ថិភាព និង សណ្តាប់ធ្នាប់សង្គម ។
- ធ្វើរបាយការណ៍ រាល់សកម្មភាពសិក្សា ជូននាយកដ្ឋានឧត្តមសិក្សានៃក្រសួងអប់រំ យុវជន និងកីឡា ឱ្យបានទៀងទាត់ តាមការកំណត់ ។

មាត្រា ៨ : និស្សិត ដែលបានរៀនចប់កម្មវិធីសិក្សារបស់សាកលវិទ្យាល័យអាយស៊ីអេស និង ទទួលបានជោគជ័យ ក្នុងការប្រលងបញ្ចប់ការសិក្សា ត្រូវទទួលសញ្ញាប័ត្រ តាមកំរិត និងតាមឯកទេសដែលបានសិក្សា ។ សញ្ញាប័ត្រនេះ ផ្តល់ឱ្យដោយសាកលវិទ្យាល័យអាយស៊ីអេស ហើយត្រូវបានទទួលស្គាល់ ពីក្រសួងអប់រំ យុវជន និងកីឡា ក្នុងករណី សាកលវិទ្យាល័យនេះ បានបំពេញ និងអនុវត្តតាមគោលការណ៍ និងបទដ្ឋានរបស់ក្រសួង អប់រំ យុវជន និងកីឡា ។

មាត្រា ៩ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា អគ្គនាយកដ្ឋាន អង្គភាពពាក់ព័ន្ធ និងសាកលវិទ្យាល័យអាយស៊ីអេស មានភារកិច្ចរៀង១ខ្លួន ដើម្បីអនុវត្តតាមអនុក្រឹត្យនេះ ។

មាត្រា ១០ : អនុក្រឹត្យនេះ មានប្រសិទ្ធភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ភ្នំពេញ ថ្ងៃទី ២៤-ខែ-៣ ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- សាលាក្រុងភ្នំពេញ

  "ដើម្បីជូនព័ត៌មាន"

- ដូចមាត្រា ៩ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១៤០ . អនក្រ . បក

អនុក្រឹត្យ

ស្តីពី

ការតែងតាំងក្រុមប្រឹក្សាភិបាល

សហគ្រាសសាធារណៈភ្នាក់ងារកម្ពុជានាវាចរ (កាំសាប)

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ជស /រកម / ០៦៩៦ /០៣ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ

-បានឃើញព្រះរាជក្រមលេខ នស / រកម /០១៩៦ /០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសាធារណការនិងដឹកជញ្ជូន

-បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ. បក ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន

-បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតសហគ្រាសសាធារណៈភ្នាក់ងារកម្ពុជានាវាចរ (កាំសាប)

-យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន

សំរេច

មាត្រា ១.- ត្រូវបានតែងតាំងក្រុមប្រឹក្សាភិបាលនៃសហគ្រាសសាធារណៈភ្នាក់ងារកម្ពុជានាវាចរសំរាប់អាណត្តិទី២ ដែលមានសមាសភាព ដូចខាងក្រោម :

១-ឯកឧត្តម	**ឡោង ធនយុទ្ធា**	តំណាងក្រសួងសាធារណការនិងដឹកជញ្ជូន	ជាប្រធាន
២-ឯកឧត្តម	**រស់ វណ្ណា**	អគ្គនាយកសហគ្រាសសាធារណៈកាំសាប	ជាសមាជិក
៣-លោក	**ឃុយ ហៀង**	តំណាងទីស្តីការគណៈរដ្ឋមន្ត្រី	ជាសមាជិក
៤-លោក	**នេត មុន្នី**	តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ	ជាសមាជិក
៥-លោក	**ស៊ាង ម៉ុនលាង**	តំណាងក្រសួងមហាផ្ទៃ	ជាសមាជិក
៦-លោក	**ឆេង សារឿន**	តំណាងក្រសួងពាណិជ្ជកម្ម	ជាសមាជិក
៧-លោក	**ញាន សុគុល**	តំណាងនិយោជិតសហគ្រាសសាធារណៈកាំសាប	ជាសមាជិក

មាត្រា ២.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុង មាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ០៣ ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចមាត្រា ២

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១៤១ អនក្រ.តត

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សំរេច

មាត្រា ១ : ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ចំនួន ០៦ គ្រឿង ប្រគេន និង ជូនសប្បុរសជន ចំនួន ០៦ រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន និ ងចលនាដឹកនាំពុទ្ធបរិស័ទ ចូលរួមជួយកសាងព្រះវិហារវត្តព្រះនង្គ័ល ស្ថិតនៅក្នុងឃុំចំណារក្រោម ស្រុកស្ទោង ខេត្តកំពង់ធំ ដូចមានរាយព្រះនាម និង នាមខាងក្រោម ÷

ក_មេដាយមាសស្ថាបនាជាតិ :

១-ព្រះតេជគុណ **ស៊ាង ស្វន** ព្រះចៅអធិការវត្តព្រះនង្គ័ល បច្ច័យ ២៣.៨០០ USD
២-ព្រះភិក្ខុ **អែម គីមហាក់** គង់នៅវត្តព្រះនង្គ័ល បច្ច័យ ១៦.៥២៥ USD
៣-ព្រះភិក្ខុ **អែម គីមហៀង** គង់នៅវត្តព្រះនង្គ័ល បច្ច័យ ១៥.៥០០ USD
៤-លោក **យឹម សុវ៉ាត** នាយកក្រុមហ៊ុន នៃតជ្រល ម៉ាញ អ៊ិនដាសស្រ្ទី អ៊ិនវេសមេនថវិកា១០០.៣៧៥ USD

ខ_មេដាយប្រាក់ស្ថាបនាជាតិ :

១-ឧបាសក **អ៊ាម ឈុន** និងឧបាសិកា **សំាង គីមឡាន់** ថវិកា ៨.៥០០ USD
២-ឧបាសក **អុំ ហុកស៊ុន** និងឧបាសិកា **សំាង ច័ន្ទស៊ូ** ថវិកា ៨.២០០ USD

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកំពង់ធំ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០០៤
នាយករដ្ឋមន្ត្រី
ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៤៥ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួង សង្គមកិច្ចការងារ បណ្តុះបណ្តាល វិជ្ជាជីវៈ និង យុវនីតិសម្បទា

ស ំ រេ ច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួន ០២ គ្រឿង ជូនមន្ត្រី នៃ ក្រុមប្រឹក្សាគំរោងកែលំអ ល័ក្ខខ័ណ្ឌ ការងារ ក្នុងវិស័យកាត់ដេរកម្ពុជា (*ILO*) ចំនួន ០២រូប ដែលបានសហការល្អជាមួយក្រសួង សង្គមកិច្ច ការងារ បណ្តុះបណ្តាល វិជ្ជាជីវៈ និង យុវនីតិសម្បទា ក្នុងការគ្រប់គ្រង កែលំអ មុខរបរកាត់ដេរ នៅកម្ពុជា អោយឈានទៅរកភាពរីកចំរើន ស្របតាមច្បាប់ការងារ និង អភិវឌ្ឍន៍ធនធានមនុស្ស ប្រកបដោយ ចិរភាព ដូចមាននាមខាងក្រោម :-

១-លោក ***Lejo Sibbel*** ប្រធានទីប្រឹក្សាបច្ចេកទេស នៃគំរោងកែលំអ ល័ក្ខខ័ណ្ឌការងារ ក្នុងវិស័យ កាត់ដេរ នៅកម្ពុជា ។

២-លោក **នុន សោភ័ណ** ជំនួយការ នៃ គំរោងកែលំអ ល័ក្ខខ័ណ្ឌការងារ ក្នុងវិស័យកាត់ដេរ នៅកម្ពុជា

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួង សង្គមកិច្ចការងារ បណ្តុះបណ្តាល វិជ្ជាជីវៈ និង យុវនីតិសម្បទា ត្រូវអនុវត្ត អនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

151

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៤៣ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួង អប់រំ យុវជន និង កីឡា

ស ម្រេ ច

មាត្រា១: ត្រូវបានបំពាក់ **មេដាយថ្នាក់ស្ថាបនាជាតិ** ជូន *Mr.Masami Kai* អ្នកស្ម័គ្រចិត្ត នៃ អង្គការ *CARE* ដែលបានផ្តល់ថវិកា ចំនួន ៧.២០៩ ដុល្លារអាមេរិក សំរាប់ជួយកសាងមជ្ឈមណ្ឌលសិក្សាវប្បធម៌កម្ពុជា-ជប៉ុន នៅស្រុកលើកដែក ខេត្តកណ្តាល ។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង អប់រំ យុវជន និង កីឡា និង អភិបាលខេត្តកណ្តាល ត្រូវអនុវត្ត អនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០០៤

ទីស្តីការគណៈរដ្ឋមន្ត្រី
នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៤៤ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួង អប់រំ យុវជន និង កីឡា

សំរេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនអង្គការផ្តល់ជំនួយ ជប៉ុន ដែលបានផ្តល់ថវិកា ជួយសាងសង់អគារសិក្សា នៅខេត្តព្រៃវែង កំពង់ស្ពឺ និង ខេត្តកំពង់ធំ ចាប់ពីឆ្នាំសិក្សា ២០០១-២០០២ ដល់ឆ្នាំសិក្សា ២០០៣-២០០៤ មានអគារសិក្សា ចំនួន ១៣៨ ខ្នង ចំណាយអស់ទឹកប្រាក់ សរុបចំនួន ៥.២៧៦.០៦៧ ដុល្លារ ដូចមាននាមខាងក្រោម :-

១-អង្គការ *Aeon Group*

២- *Japan Committee for UNICEF*

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួង អប់រំ យុវជន និង កីឡា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

140

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៤៥ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួង អប់រំ យុវជន និង កីឡា

សំ រេ ច

មាត្រា១: ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ជប៉ុន ចំនួន ០២រូប ដែលបានផ្តល់ជំនួយជាថវិកា សរុប ចំនួន ១២០.០០០ ដុល្លារ សំរាប់ជួយដល់ សិស្សានុសិស្សក្រីក្រ នៅសាលាបឋមសិក្សា នៃកំរងសាលាទាំងបី ក្នុងស្រុកលើកដែក ខេត្តកណ្តាល ដូចមាននាមខាងក្រោម :-

១-*Mr. Satoshi TAMAKUMA* មកពី អង្គការឃែរ ជប៉ុន
២-*Ms. Sharon Wilkinson* មកពី អង្គការឃែរ ជប៉ុន

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង អប់រំ យុវជន និង កីឡា និង អភិបាលខេត្តកណ្តាល ត្រូវអនុវត្ត អនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៤៦ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២០២/០៤០ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០២ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
- បានឃើញអនុក្រឹត្យលេខ ៣០ អនក្រ.បក ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ ២០០២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
- យោងតាមសំណើរបស់ អនុប្រធានទី១ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

សំរេច

មាត្រា១ : ត្រូវបានតែងតាំងលោក **ម៉ិច លាងហ៊ី** ជាប្រធាននាយកដ្ឋានត្រៀមរៀបចំ និងបណ្តុះបណ្តាល នៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ។

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អនុប្រធានទី១-គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារ-សាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែ មីនា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៤៧ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយការងារ

&&&&&

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត / ១០៩៥ / ០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ប្រធានកាកបាទក្រហមកម្ពុជា

សំរេច

មាត្រា ១ : ត្រូវបានបំពាក់ **មេដាយមាសការងារ** ជូនឥស្សរជនបរទេសចំនួន ០៤ រូប ដែលមានស្នាដៃល្អ និង គុណបំណាច់ខ្ពស់ ក្នុងការសហការបំពេញការងារមនុស្សធម៌ ជាមួយកាកបាទក្រហមកម្ពុជា ដូចមានរាយនាមខាងក្រោម ÷

១-Mr. **Kalevi Johannes Kiviso**	ប្រធានកាកបាទក្រហមហ្វាំងឡង់
២-Mr. **Ray Worner**	ទីប្រឹក្សានៃកម្មវិធីប្រព័ន្ធពត៌មានជនរងគ្រោះដោយសារមីន និង គ្រាប់មិនទាន់ផ្ទុះ
៣-Mr. **Marc Hermant**	នាយកនៃអង្គការជនពិការអន្តរជាតិ (HI)
៤-Ms. **Tianji Dicken**	អ្នកស្ម័គ្រចិត្តតាមកម្មវិធី Australian Youth Ambassador

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ប្រធានកាកបាទក្រហមកម្ពុជា ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និង មាត្រា២
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៤៧ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃ ព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួង ឧស្សាហកម្ម រ៉ែ និង ថាមពល

សំរេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន ០២រូប ដែលបានឧបត្ថម្ភប្រព័ន្ធថាមពលព្រះអាទិត្យ រួមចំណែកក្នុងការអភិវឌ្ឍន៍ប្រទេសកម្ពុជា នៅតាមមូលដ្ឋានមួយចំនួន ក្នុងខេត្តក្រចេះ ខេត្តកំពង់ចាម ខេត្តបន្ទាយមានជ័យ និង ខេត្តកណ្តាល ដូចមានរាយនាមខាងក្រោមនេះ :-

១-លោក **យ៉ូស៊ីគី តាកេអូកា** (Mr *YOSHIKI TAKEOKA*) ប្រធានក្រុមហ៊ុន *KANEKA* ប្រទេសជប៉ុន បានឧបត្ថម្ភ ឧបករណ៍សំភារៈ ថាមពលព្រះអាទិត្យ នៅស្ពានកំពង់រាំង និង ស្ពានដើមស្តៅ ចំណាយអស់ទឹកប្រាក់ចំនួន ១២.៦០០ ដុល្លារ ។

២-លោក **ស៊ូ ឈុលស៊ីន** (Mr *SOO CHUL SHIN*) ប្រធានសាជីវកម្ម *POSCON Corporation* សាធារណរដ្ឋកូរ៉េ ជួយឧបត្ថម្ភ ថវិកា ចំនួន ១១.៣០០ ដុល្លារ សំរាប់អនុវត្ត នូវទីតាំង វិទ្យាល័យ សម្តេច ហេង សំរិន សាលាបឋមសិក្សា ចំណោម ស្ពានបាយណ៏ ស្ពានបឹងគ្រាម និង មណ្ឌលសុខភាព ឃុំពាមកោះស្នា ។

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង ឧស្សាហកម្ម រ៉ែ និង ថាមពល . អភិបាលខេត្តក្រចេះ ខេត្តកំពង់ចាម ខេត្តបន្ទាយមានជ័យ និង ខេត្តកណ្តាល ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១៤៩ អនក្រ.តត

អនុក្រឹត្យ
ស្តីពី
ការតម្លើងឋានន្តរសក្តិនាយនគរបាលជាតិ ជាកិច្ចបច្ឆាមរណៈ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- យោងតាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សំរេច

មាត្រា១ : ត្រូវបានតម្លើងឋានន្តរសក្តិថ្នាក់ **ឧត្តមសេនីយ៍ឯក** ជាកិច្ចបច្ឆាមរណៈ ជូនចំពោះសពលោកវរសេនីយ៍ទោ **សែម ជា** អត្តលេខ ០៤៨១ ស្នងការរង និងជាប្រធានសេនាធិការដ្ឋាន នៃស្នងការដ្ឋាននគរបាលក្រុងប៉ៃលិន ។

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- កាលប្បវត្តិ - ឯកសារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៥០ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃ ព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រី ក្រសួង សាធារណការ និង ដឹកជញ្ជូន

សំ រេ ច

មាត្រា១: ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនអង្គភាព និង មន្ត្រីរាជការ ក្រោមឱវាទក្រសួង សាធារណការ និង ដឹកជញ្ជូន ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ច ស្តារ និង ជួសជុលកំណាត់ផ្លូវជាតិលេខ៨ (កំពង់ចម្លង-បាក់ដាវ) ដូចមានរាយនាមខាងក្រោម :-

ក-មេដាយមាសការងារ :

-អង្គភាព **មូលដ្ឋានស្ពានថ្នល់**

ខ-មេដាយប្រាក់ការងារ :

១-លោក **ជាង គឹមឃុល** នាយការិយាល័យគណនេយ្យ-ផែនការ ម.គ.ធ

២-លោក **ឈាង ស៊ីមអឿន** នាយការិយាល័យរដ្ឋបាល បុគ្គលិក ធនធានមនុស្ស ម.គ.ធ

គ-មេដាយសំរិទ្ធការងារ :

១-លោក **មិន រ៉ាវី** អ្នកគ្រប់គ្រងឃ្លាំង

២-លោក **ជា សាត** ជំនួយយន្តការី

៣-លោក **មាឃ ម៉ុន** ជំនួយយន្តការី

៤-លោក **នួន សំអុល** ជំនួយយន្តការី

៥-លោក **ម៉ាន់ ពុំ** អ្នកបើកបរនីវ៉ូឡឺ

៦-លោក **សួន គឹមលី** អ្នកបើកបររូឡូញាក់

៧-លោក **ជា ជឺន** អ្នកបើកបររូឡូញាក់

៨-លោក **អេង ឈន** អ្នកបើកបររូឡូញាក់

៩-លោក **សៀង សំអាត** អ្នកបើកបរសាហ៊្វារ៉

១០-លោក ស៊ុត សន អ្នកបើកបរសាប៊្យូរ៉
១១-លោក ប៊ុន សុខឡឿន អ្នកបើកបរអេចស្កាវ៉ាទ័រ
១២-លោក ស្វាយ អេន អ្នកបើកបរត្រាក់ទ័រ
១៣-លោក ហ៊ី លន់ អ្នកជំនួយបើកបរត្រាក់ទ័រ
១៤-លោក អៀន ប៊ុរិទ្ធ អ្នកបើកបររថយន្តបែន
១៥-លោក អ៊ុន សារ៉េត អ្នកបើកបររថយន្តដឹកទឹក
១៦-លោក ប៊ិច ឆែលន អ្នកជំនួយបើកបររថយន្តដឹកទឹក
១៧-លោក ឈុន ទិន អ្នកបើកបររថយន្តស្រោចកៅស៊ូ
១៨-លោក ប្រាក់ ឈឿន អ្នកបើកបររថយន្ត
១៩-លោក ឃីន់ ស៊ីថុន អ្នកបើកបររថយន្ត
២០-កញ្ញា មាច ស៊ុត កម្មការិនី
២១-កញ្ញា យ៉ន ឆឿន កម្មការិនី
២២-កញ្ញា អ៊ូ សុខហ៊ីយ កម្មការិនី
២៣-អ្នកស្រី គុយ សុផាត កម្មការិនី
២៤-អ្នកស្រី សេខ ស៊ីន្ធី កម្មការិនី
២៥-អ្នកស្រី យិន សុគន្ធា កម្មការិនី
២៦-លោក ទ៉ាត ប៊ូ សន្តិសុខ
២៧-លោក ស្ងួន ថុល សន្តិសុខ
២៨-លោក ស៊ឿន លាងអួន សន្តិសុខ
២៩-លោកព្រិន្ទបាលឯក ម៉ក់ សារ៉ាវុធ នគរបាល
៣០-លោកពលបាលត្រី ម៉ោក មាន នគរបាល

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រី ក្រសួងសាធារណការ និង ដឹកជញ្ជូន ត្រូវអនុវត្ត អនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៥១ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃ ព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ សហរដ្ឋមន្ត្រី ក្រសួង មហាផ្ទៃ

សំ រេ ច

មាត្រា១: ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ប្រគេន ព្រះវិចិត្រសត្ថា **ច្រឹក អេង** រាជាគណៈ ថ្នាក់កិត្តិយស ទីប្រឹក្សាសម្តេចព្រះសង្ឃរាជ និង ជាចៅអធិការវត្ត *សុវណ្ណរាសីរតនារាម* ឃុំសំរោង ស្រុកពញាឮ ខេត្តកណ្តាល ដែលមានស្នាព្រះហស្តល្អ ក្នុងការចូលរួមកសាង និង អភិវឌ្ឍន៍ វិស័យព្រះពុទ្ធសាសនា សង្គមកិច្ច អប់រំ និង គមនាគមន៍ នៅស្រុកពញាឮ ខេត្តកណ្តាល ។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ និង អភិបាលខេត្តកណ្តាល ត្រូវអនុវត្ត អនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ ៣ ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១៥៧ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃ ព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួង សង្គមកិច្ច ការងារ បណ្តុះបណ្តាល វិជ្ជាជីវៈ និង យុវនីតិសម្បទា

សំរេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក **ញៀវ សិតសុផារី** អគ្គនាយកអង្គការប្រព័ន្ធទិន្នន័យកម្ពុជា (***Digital Divide Data - DDD***) ដែលបានធ្វើសកម្មភាពមនុស្សធម៌ ជួយដល់ជនពិការ កុមារកំព្រា ស្ត្រីមានវិបត្តិ និង ជនក្រីក្រកម្ពុជា ដូចជាជួយរកការងារអោយធ្វើ ជួយបណ្តុះបណ្តាលមុខជំនាញវិជ្ជាជីវៈ ។ល។ ចាប់តាំងពីថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០០២ រហូតដល់បច្ចុប្បន្ន ចំណាយអស់ទឹកប្រាក់ជំនួយ ចំនួន ៦៩០.០០០ ដុល្លារ ។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួង សង្គមកិច្ច ការងារ បណ្តុះបណ្តាល វិជ្ជាជីវៈ និង យុវនីតិសម្បទា ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ ០២ ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៥៣ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃ ព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ សហរដ្ឋមន្ត្រី ក្រសួង មហាផ្ទៃ

ស ម្រេ ច

មាត្រា១: ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន ០២រូប ដែលបានបរិច្ចាគធនធាន ចូលរួមជួយកសាង សមិទ្ធផលផ្សេងៗ នៅវត្តសុវណ្ណរាសីរតនារាម ក្នុងឃុំសំរោង ស្រុកពញាឮ ខេត្តកណ្តាល ដូចមានរាយនាមខាងក្រោម :-

១-ឧកញ៉ា **ហែម ថេង** នៅក្រុងភ្នំពេញ ទឹកប្រាក់ ចំនួន ១៥.៨៥០ ដុល្លារ

២-លោកជំទាវ **សាន អរុណ** អនុរដ្ឋលេខាធិការ ក្រសួងកិច្ចការនារី និង អតីត យុទ្ធជន ទឹកប្រាក់ ចំនួន ១២.១៥០ ដុល្លារ

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ និង អភិបាលខេត្តកណ្តាល ត្រូវអនុវត្ត អនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ...១៥៤...អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃ ព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រី ក្រសួង ធម្មការ និង សាសនា

សំរេច

មាត្រា១: ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ចំនួន ១២ គ្រឿង ប្រគេន និង ជូនសប្បុរសជន ចំនួន ១២ រូប ដែលបានខិតខំបំផុសចលនា ពុទ្ធបរិស័ទ និង បរិច្ចាគបច្ច័យ និង ថវិកា ចូលរួម ជួយកសាងកុដិ ០១ខ្នង ធ្វើរបងវត្ត កែលំអព្រះវិហារ និង កសាងសមិទ្ធផលមួយចំនួនទៀត នៅក្នុងវត្តឧត្តរាវតី ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ដូចមានរាយព្រះនាម និង នាមខាងក្រោមនេះ :-

ក-មេដាយមាសស្ថាបនាជាតិ :

១-ភិក្ខុ ម៉ុក ម៉ិនសុធា	ព្រះចៅអធិការវត្តឧត្តរាវតី	បច្ច័យ ចំនួន ១២.៨៥០ ដុល្លារ
២-លោកជំទាវ សោម នឿន	ភរិយា ឯកឧត្តម សូ ឃុន	ថវិកា ចំនួន ១២.៤៣០ ដុល្លារ
៣-លោកជំទាវ ស្រី ទុន្ធី	ភរិយា ឧកញ៉ា ស្រី ខួន	ថវិកា ចំនួន ១២.២២០ ដុល្លារ

ខ-មេដាយប្រាក់ស្ថាបនាជាតិ :

១-ភិក្ខុ អ៊ុំ ឈឿន	គ្រូសូត្រឆ្វេង វត្តឧត្តរាវតី	បច្ច័យ ចំនួន ៨.៤៨០.៥០ ដុល្លារ
២-លោក អ៊ុក ម៉ាច	ចៅសង្កាត់ឫស្សីកែវ	ថវិកា ចំនួន ៨.០៧៥ ដុល្លារ
៣-លោក អ៊ិន ណាវ	អាចារ្យវត្តឧត្តរាវតី	ថវិកា ចំនួន ៨.២៣៥ ដុល្លារ
៤-លោក ភឿក ភួយ	អាចារ្យវត្តឧត្តរាវតី	ថវិកា ចំនួន ៨.៣៦៥ ដុល្លារ
៥-លោក សរ ជន់	គណៈកម្មការវត្តឧត្តរាវតី	ថវិកា ចំនួន ៧.៨២៥ ដុល្លារ
៦-លោក អ៊ុច សាមិន	សប្បុរសជន	ថវិកា ចំនួន ៧.៨៨០ ដុល្លារ
៧-លោក កោ នាថ	សប្បុរសជន	ថវិកា ចំនួន ៨.១៧០ ដុល្លារ

គ-មេជាងសិល្បស្ថាបនាជាតិ :

១-លោក **ហង់ ហាន** សប្បុរសជន ថវិកា ចំនួន ៤.៣០០ ដុល្លារ

២-លោក **គឹម លឹមជី** សប្បុរសជន ថវិកា ចំនួន ៤.១៥០ ដុល្លារ

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា និង អភិបាលរាជធានីភ្នំពេញ ត្រូវ អនុវត្តអនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ០២ ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ..១៥៥..អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃ ព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រី ក្រសួង ធម្មការ និង សាសនា

សំរេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ចំនួន០៩គ្រឿង ប្រគេន និង ជូនសប្បុរសជន ចំនួន ០៩រូប ដែលបានខិតខំចលនា ពុទ្ធបរិស័ទ និងបានបរិច្ចាគបច្ច័យ និង ថវិកា ចូលរួមជួយកសាង ក្លោងទ្វារ ចំនួន០៣ ប្រាសាទ ចំនួន០៤ រោងតម្កល់សព របង ផ្លូវបេតុង និង សមិទ្ធផលមួយចំនួនទៀត នៅក្នុងវត្តសំរោងអណ្តែត សង្កាត់ភ្នំពេញថ្មី ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ដូចមានរាយព្រះនាម និង នាមខាងក្រោមនេះ :-

ក-មេដាយមាសស្ថាបនាជាតិ :

១-ព្រះសក្យវង្ស **វន្ត សារឿន** រាជាគណៈថ្នាក់ត្រី និង ជាទីប្រឹក្សាសម្តេចព្រះសង្ឃរាជគណៈមហានិកាយ បច្ច័យ ចំនួន ៧២.៥០៣ ដុល្លារ

២-លោក **ហាញ់ ចំរុង** នាយករងពុទ្ធិកវិទ្យាល័យ វត្ត សារឿន ថវិកា ចំនួន ១៣.០០០ ដុល្លារ

៣-លោក **ហាញ់ ចំរើន** ប្រធានគណៈកម្មការសាងសង់វត្តសំរោងអណ្តែត ថវិកា ចំនួន ១២.៥០០ ដុល្លារ

៤-លោក **សរ សេរីមិត្រ** អនុប្រធានប៉ុស្តិ៍ ច្រកទ្វារអន្តរជាតិភ្នំពេញ ថវិកា ចំនួន ១២.៣០០ ដុល្លារ

ខ-មេដាយប្រាក់ស្ថាបនាជាតិ :

១-លោក **ជុំ សារ៉ាយ** ចៅសង្កាត់ភ្នំពេញថ្មី ថវិកា ចំនួន ៨.១០០ ដុល្លារ

២-ភិក្ខុ **អ៊ុយ ហើស** ទីប្រឹក្សាមន្ត្រីសង្ឃ វត្តសំរោងអណ្តែត បច្ច័យ ចំនួន ៨.១៩៥ ដុល្លារ

៣-ភិក្ខុ **យ៉ា ឡុង** មន្ត្រីសង្ឃ វត្តសំរោងអណ្តែត បច្ច័យ ចំនួន ៨.២៧៥ ដុល្លារ

៤-លោក **ឃ្លាំង សោភ័ណ** ទីប្រឹក្សាព្រះសក្យវង្ស ថវិកា ចំនួន ៨.០៥០ ដុល្លារ

៥-លោក **ជា ចៀង** អនុប្រធានគណៈកម្មការសាងសង់វត្តសំរោងអណ្តែត ថវិកា ចំនួន ៧.៥៣០ ដុល្លារ

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា និង អភិបាលរាជធានីភ្នំពេញ ត្រូវ អនុវត្តអនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ០៥៦ អនក្រ-តត

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួង មហាផ្ទៃ

ស ម្រ េ ច

មាត្រា១: ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** ប្រគេន និង ជូន សប្បុរសជន ចំនួន ០៥ រូប ដែលបានបរិច្ចាគធនធាន ជួយកសាងសមិទ្ធផលនានា នៅវត្តពោធិខ្សាច់អារ្យ ស្រុកល្វាឯម ខេត្តកណ្តាល និង អនុវិទ្យាល័យសុខ អាន ពោធិរំចាក ស្រុកព្រៃកប្បាស ខេត្តតាកែវ ដូចមានរាយព្រះនាម និង នាមខាងក្រោម :-

ក_មេដាយមាសស្ថាបនាជាតិ :

១-ព្រះតេជគុណ **ឡុង សំណាង** ចៅអធិការវត្តពោធិខ្សាច់អារ្យ

២-លោក **តាំង ខួនសុខ** ប្រធានក្រុមហ៊ុន *TNS Group International Consultant Co.Ltd* ថវិកាចំនួន ១០០.១៧០ ដុល្លារ

ខ_មេដាយសំរឹទ្ធស្ថាបនាជាតិ :

១-លោក **យាន ហុកឃីម** នៅក្រុងភ្នំពេញ ថវិកា ចំនួន ១.៦៥០ ដុល្លារ

២-លោកស្រី **ហេង សារ៉េត** នៅក្រុងភ្នំពេញ ថវិកា ចំនួន ១.៣៥០ ដុល្លារ

៣-លោក **ថន តារា** នៅក្រុងភ្នំពេញ ថវិកា ចំនួន ១.៥០០ ដុល្លារ

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលខេត្តកណ្តាល និង អភិបាលខេត្តតាកែវ ត្រូវអនុវត្ត អនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ។

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ ៣ ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចក្នុងមាត្រា១ និងមាត្រា២

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

117

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១១ សរសរ

សេចក្តីសម្រេច
ស្តីពី
ការរៀបចំកិច្ចប្រជុំនៃក្រុមពិគ្រោះយោបល់លើកទី៧

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ នស/ ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ. បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យរបស់រាជរដ្ឋាភិបាល លេខ ៧០ អនក្រ. បក ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- តាមសំណើរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអនុប្រធានទី ១ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

សម្រេច

ប្រការ ១ : ប្រគល់ភារកិច្ចជូនឯកឧត្តម គាត ឈន់ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអនុប្រធានទី១នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងការដឹកនាំនិងសំរបសំរួលការងារត្រៀមរៀបចំ សំរាប់កិច្ចប្រជុំនៃក្រុមពិគ្រោះយោបល់លើកទី ៧ ដែលនឹងប្រព្រឹត្តទៅក្នុងឆ្នាំ ២០០៤ នេះ ។

ប្រការ ២ : ក្នុងក្របខ័ណ្ឌនៃការដឹកនាំនិងសំរបសំរួលការងារត្រៀមរៀបចំសំរាប់កិច្ចប្រជុំនេះ ឯកឧត្តម **គាត ឈន់** ត្រូវសហការជាមួយប្រធាននៃបណ្តាក្រសួងនិងស្ថាប័នទាំងអស់របស់រាជរដ្ឋាភិបាល និងមានសិទ្ធិអញ្ជើញមន្ត្រីជាន់ខ្ពស់អោយចូលរួមប្រជុំអន្តរក្រសួង និងមានសិទ្ធិចាត់ចែងពិគ្រោះយោបល់ជាមួយតំណាងប្រទេសនិងអង្គការអន្តរជាតិអ្នកផ្តល់ជំនួយទ្វេភាគី និងពហុភាគី ដើម្បីសំរបសំរួលការងារ និងដើម្បីរៀបចំសេចក្តីព្រាងឯកសារចាំបាច់ៗនានា ។

ប្រការ ៣ : ឯកឧត្តម **គាត ឈន់** ត្រូវរាយការណ៍ជាបន្តបន្ទាប់ជូនសម្តេចនាយករដ្ឋមន្ត្រី អំពីវឌ្ឍនភាពនៃការរៀបចំ ហើយត្រូវរៀបចំឯកសារចាំបាច់នានាសំរាប់កិច្ចប្រជុំលើកទី ៧ នេះ ដើម្បីដាក់ជូនសម្តេចនាយករដ្ឋមន្ត្រីពិនិត្យ ផ្តល់យោបល់ណែនាំ និងអនុម័ត មុននឹងយកទៅប្រើប្រាស់ជាផ្លូវការ ។

ប្រការ ៤ :ក្នុងការបំពេញកិច្ចការនេះ ឯកឧត្តម **គាត ឈន់** ប្រើប្រាស់រចនាសម្ព័ន្ធរបស់គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា (កអក/គជនា) ដែលមានឯកឧត្តម **ឈឿង យ៉ាណរ៉ា** ជាអគ្គលេខាធិការ សំរាប់ជំនួយការងារប្រចាំថ្ងៃ ។

ប្រការ ៥ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រី និងរដ្ឋលេខាធិការគ្រប់ក្រសួងនិងស្ថាប័នពាក់ព័ន្ធ និងឯកឧត្តម **គាត ឈន់** ត្រូវអនុវត្តតាមសេចក្តីសំរេចនេះ អោយមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ប្រការ ៦ : សេចក្តីសំរេចនេះអោយមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខារហូតដល់កិច្ចប្រជុំលើកទី៧នៃក្រុមពិគ្រោះយោបល់បានប្រព្រឹត្តទៅចប់សព្វគ្រប់ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មិនា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធិសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ដូចប្រការ៥ " ដើម្បីអនុវត្ត "
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១២ . សសរ

សេចក្តីសម្រេច

ស្តីពី

ការបង្កើតក្រុមការងារពិសេសអន្តរក្រសួង-ស្ថាប័ន ដើម្បីកែលំអបរិស្ថានវិនិយោគ និងសម្រួលពាណិជ្ជកម្ម

រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី ០៥ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និង ព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី ២៤ ខែមិនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៧០ អនក្រ/បក ចុះថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញសេចក្តីសម្រេច លេខ ៤៤ សសរ ចុះថ្ងៃទី ០៣ ខែសីហា ឆ្នាំ២០០១ និង ៤១ សសរ ចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ២០០២ ស្តីពីការបង្កើតក្រុមការងារតាមវិស័យ
- យោងស្មារតីនៃកិច្ចប្រជុំពេញអង្គរបស់គណៈរដ្ឋមន្ត្រី នៅថ្ងៃទី ២៧ ខែកុម្ភៈ ឆ្នាំ២០០៤ ស្តីពីកម្មវិធីការងារសំរាប់អនុវត្តកាតព្វកិច្ចរបស់កម្ពុជា នៅក្នុងក្របខ័ណ្ឌអង្គការពាណិជ្ជកម្មពិភពលោក
- យោងតាមស្មារតីអង្គប្រជុំអន្តរក្រសួង នៅថ្ងៃទី ១៨ ខែមិនា ឆ្នាំ២០០៤

សំ រេ ច

ប្រការ ១ : បង្កើតក្រុមការងារពិសេសអន្តរក្រសួង-ស្ថាប័នដើម្បីកែលំអបរិស្ថានវិនិយោគ និងសំរួលពាណិជ្ជកម្ម ដែលមានសមាសភាពដូចខាងក្រោម :

១-	ឯកឧត្តម **គាត ឈន់** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	ប្រធាន
២-	ឯកឧត្តម **ចម ប្រសិទ្ធ** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម	អនុប្រធាន
៣-	ឯកឧត្តម **ស៊ុយ សែម** រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល	សមាជិក
៤-	ឯកឧត្តម **ចាន់ សារុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ	សមាជិក
៥-	ឯកឧត្តម **ញ៉ែ សុខា** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ	សមាជិក
៥-	ឯកឧត្តម **ប៉ែន ស៊ីម៉ន** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកទីចាត់ការគយ និងរដ្ឋាករ	សមាជិក
៧-	ឯកឧត្តម **លូ គឹមឈុន** ប្រធានអគ្គនាយកកំពង់ផែស្វយ័តក្រុងព្រះសីហនុ	សមាជិក
៦-	លោក **ហុង ថាវ** ប្រធាននាយកដ្ឋានពន្ធដារ	សមាជិក
៧-	លោក **ស៊ុន តារា** ប្រធាននាយកដ្ឋានកាំកុងត្រូល	សមាជិក
៨-	លោក **ស៊ាន ម៉ិនឈាង** អនុប្រធានទី១នៃនាយកដ្ឋាននគរបាលសេដ្ឋកិច្ច	សមាជិក
៩-	ឯកឧត្តម **សុខ ចិន្តា** អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា	លេខាធិការ

ប្រការ ២ : ក្រុមការងារពិសេសអន្តរក្រសួង-ស្ថាប័នដើម្បីកែលំអបរិស្ថានវិនិយោគ និងសំរួលពាណិជ្ជកម្ម មានភារកិច្ចជាបន្ទាន់ដូចតទៅ :

ទី១- លើក ហើយដាក់ឱ្យអនុវត្តនូវវិធានការកាត់បន្ថយចំណាយជាប្រាក់ សំរាប់អន្តរការីយកម្មក្នុងការនាំចេញ ការនាំចូល ។

ទី២- លើក ហើយដាក់ឱ្យអនុវត្តនូវវិធានការកាត់បន្ថយបែបបទ ឬលុបចោលបែបបទដែលជាន់គ្នា ក្នុងការគ្រប់គ្រងកិច្ចដំណើរការពាណិជ្ជកម្ម ។

ទី៣- លើក ហើយដាក់ឱ្យអនុវត្តនូវវិធានការកាត់បន្ថយពេលវេលាក្នុងការនាំចេញ ការនាំចូលទំនិញ ។

ទី៤- លើក ហើយដាក់ឱ្យអនុវត្តនូវរាល់វិធានការបង្កើនចំណូលចូលថវិការដ្ឋ ។

រាល់វិធានការនៃភារកិច្ចទី១ ទី២ និងទី៣ ខាងលើនេះ គ្រាន់តែជាផ្នែកមួយនៃកាតព្វកិច្ចរបស់កម្ពុជាក្នុងឋានៈជាសមាជិករបស់អង្គការពាណិជ្ជកម្មពិភពលោកដែលក្រសួងពាណិជ្ជកម្មបាននិងកំពុងដឹកនាំបំពេញតាមការសំរេចរបស់គណៈរដ្ឋមន្ត្រី នៅថ្ងៃទី ២៧ ខែកុម្ភៈ ឆ្នាំ២០០៤ ។

ប្រការ ៣ : ភារកិច្ចខាងលើនេះ ត្រូវសំរេចឱ្យបានជាលទ្ធផលដែលគេអាចគណនាជាតួលេខបាន ។

ប្រការ ៤ : ក្រុមការងារពិសេសត្រូវរាយការណ៍ជាប្រចាំជូនប្រមុខរាជរដ្ឋាភិបាល អំពីបណ្តាវិធានការនានាដែលបានដាក់ចេញ ។ ក្នុងករណីដែលមានវិធានការលើសសមត្ថកិច្ចរបស់ខ្លួន ក្រុមការងារពិសេសត្រូវរាយការណ៍ សុំការណែនាំ និងការសំរេចពីប្រមុខរាជរដ្ឋាភិបាល ។

ប្រការ ៥ : ប្រធានក្រុមការងារពិសេសអាចអញ្ជើញថ្នាក់ដឹកនាំក្រសួង-ស្ថាប័ន អង្គភាពពាក់ព័ន្ធមកចូលរួមការងារបាន ។ ពេលប្រធានអវត្តមាន ក្រុមការងារអាចប្រជុំក្រោមអធិបតីភាពរបស់អនុប្រធាន ឬ របស់តំណាងតាមការប្រគល់សិទ្ធិរបស់ប្រធាន ។

ប្រការ ៦ : ក្នុងករណីចាំបាច់ក្រុមការងារនេះ អាចសហការជាមួយអ្នកផ្តល់ជំនួយ និង/ឬ ភាគីពាក់ព័ន្ធមកពីវិស័យឯកជន ដើម្បីសំរេចបានប្រកបដោយប្រសិទ្ធភាពនូវភារកិច្ចខាងលើ ។

ប្រការ ៧ : ក្រុមការងារពិសេសនេះ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

ប្រការ ៨ : អាណត្តិរបស់ក្រុមការងារនឹងបញ្ចប់នៅពេលដែលយន្តការរបស់រាជរដ្ឋាភិបាលអំពីការដឹកនាំអនុវត្តយុទ្ធសាស្ត្រ អភិវឌ្ឍន៍វិស័យឯកជន និងកម្មវិធីកែលំអបរិយាកាសវិនិយោគនៅកម្ពុជាត្រូវបានកំណត់ឡើង ។ ក្នុងន័យនេះ ក្រុមការងារត្រូវលើកសំណើជូនប្រមុខរាជរដ្ឋាភិបាលស្តីពីយន្តការនេះ ក្នុងរយៈពេលយ៉ាងខ្លីបំផុត ។

ប្រការ ៩ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងសមាសភាពដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសំរេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មីនា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>ចម្លងជូន:</u>

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ៩*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

លេខ 003/04 គ.ជ.ប

សេចក្តីសម្រេច

ស្តីពីការលុបឈ្មោះបេក្ខជនជាប់ឆ្នោតតំណាងរាស្ត្រ គណបក្ស ប្រជាជនកម្ពុជា

ចេញពីមណ្ឌលខេត្ត កំពង់ចាម

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រម នស/រកម/១២៩៧.០៦ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីការប្រកាសឱ្យប្រើច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។
- បានឃើញព្រះរាជក្រម នស/រកម/០៩០២/០១៧ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០២ ស្តីពីវិសោធនកម្មច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។
- បានឃើញព្រះរាជក្រម ជស/រកម/១៩៧/០៧ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ស្តីពីការប្រកាសឱ្យប្រើច្បាប់ស្តីពីគណបក្សនយោបាយ ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០០២/៣០០ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០០២ ស្តីពីការតែងតាំងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី ៣ ។
- បានឃើញសេចក្តីសម្រេចលេខ ០៥.២៣២/០៣ គ.ជ.ប. ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០០៣ ស្តីពីការទទួលស្គាល់ជាផ្លូវការការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ ។
- បានឃើញសេចក្តីសម្រេចលេខ ០៨.៥១៧/០៣ គ.ជ.ប. ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០៣ ស្តីពីការប្រកាសបេក្ខជនជាប់ឆ្នោតជាតំណាងរាស្ត្រក្នុងសម័យបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិ ទី ៣ ។
- បានឃើញលិខិតលេខ ៤៨៤ លគ.គក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៤ ស្តីពីការសុំប្រកាសទទួលស្គាល់បេក្ខជនជាប់ឆ្នោតថ្មីរបស់គណបក្ស ប្រជាជនកម្ពុជា ។

សម្រេច

ប្រការ១ : លុបឈ្មោះឯកឧត្តម **ម៉ាត់ លី** ភេទ ប្រុស អាយុ ៧៣ ឆ្នាំ បេក្ខជនជាប់ឆ្នោតតំណាងរាស្ត្រ គណបក្ស **ប្រជាជនកម្ពុជា** ចេញពីបញ្ជីបេក្ខជនឈរឈ្មោះនៅមណ្ឌលខេត្ត **កំពង់ចាម** ដែលបានទទួលមរណភាពកាលពីថ្ងៃទី០៦ ខែមីនា ឆ្នាំ២០០៤ ។

ប្រការ២ : គណបក្សនយោបាយសាមី អគ្គលេខាធិការដ្ឋាន និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ត្រូវអនុវត្តសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាព ។

ប្រការ៣ : សេចក្តីសម្រេចនេះមានអានុភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ ថ្ងៃទី23 ខែ មីនា ឆ្នាំ ២០០៤

ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

ប្រធាន

អ៊ឹម សួស្តី

ចម្លងជូនថ្វាយ
- ព្រះមហាក្សត្រ

ចម្លងជូន
- ក្រុមប្រឹក្សាធម្មនុញ្ញ
- ព្រឹទ្ធសភា
- រដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- មជ្ឈមណ្ឌលតម្កល់ឯកសារជាតិ
- គណបក្សនយោបាយ "ដើម្បីជូនជ្រាប"
- ដូចប្រការ ២ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

លេខ 004/04 គ.ជ.ប

សេចក្ដីប្រកាស
ឯកឧត្តម ជិន គឹមស្រេង បេក្ខជនតំណាងរាស្ត្រជាប់ឆ្នោត របស់គណបក្សប្រជាជនកម្ពុជា នៅមណ្ឌលខេត្ត កំពង់ចាម

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រម នស/រកម/១២៩៧.០៦ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ១៩៩៧ ស្ដីពីការប្រកាសឱ្យប្រើច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។
- បានឃើញព្រះរាជក្រម នស/រកម/០៩០២/០១៧ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០២ ស្ដីពីវិសោធនកម្មច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។
- បានឃើញព្រះរាជក្រម ជស/រកម/១៩៧/០៧ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ស្ដីពីការប្រកាសឱ្យប្រើច្បាប់ស្ដីពីគណបក្សនយោបាយ ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០០២/៣០០ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០០២ ស្ដីពីការតែងតាំងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី ៣ ។
- បានឃើញសេចក្ដីសម្រេចលេខ ០៥.២៣២/០៣ គ.ជ.ប. ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០០៣ ស្ដីពីការទទួលស្គាល់ជាផ្លូវការការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ ។
- បានឃើញសេចក្ដីសម្រេចលេខ ០៨.៥១៧/០៣ គ.ជ.ប. ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០៣ ស្ដីពីការប្រកាសបេក្ខជនជាប់ឆ្នោតជាតំណាងរាស្ត្រក្នុងសម័យបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិ ទី ៣ ។
- បានឃើញលិខិតលេខ ៤៨៨ លគ.គក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៤ ស្ដីពីការសុំប្រកាសទទួលស្គាល់ឯកឧត្ដម **ជិន គឹមស្រេង** ជំនួសឯកឧត្ដម **ម៉ាត់ ឈី** បេក្ខជនជាប់ឆ្នោតតំណាងរាស្ត្រនៃគណបក្ស **ប្រជាជនកម្ពុជា** ។
- បានឃើញសេចក្ដីសម្រេចលេខ 003/04 គ.ជ.ប. ចុះថ្ងៃទី 23 ខែ មីនា ឆ្នាំ ២០០៤ ស្ដីពីការលុបឈ្មោះឯកឧត្ដម **ម៉ាត់ ឈី** ចេញពីបញ្ជីបេក្ខជនជាប់ឆ្នោតតំណាងរាស្ត្រ គណបក្ស **ប្រជាជនកម្ពុជា** មណ្ឌលខេត្ត **កំពង់ចាម** ។

ប្រកាស

ប្រការ១ : ឯកឧត្ដម **ជិន គឹមស្រេង** ភេទ ប្រុស អាយុ ៦៣ ឆ្នាំ ជាបេក្ខជនតំណាងរាស្ត្រជាប់ឆ្នោត គណបក្ស **ប្រជាជនកម្ពុជា** មណ្ឌលខេត្ត **កំពង់ចាម** ។

ប្រការ២ : គណបក្សនយោបាយសាមី អគ្គលេខាធិការដ្ឋាន និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ត្រូវអនុវត្តសេចក្ដីសម្រេចនេះ ឱ្យមានប្រសិទ្ធភាព ។

ប្រការ៣ : សេចក្ដីសម្រេចនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ ថ្ងៃទី23 ខែ មីនា ឆ្នាំ ២០០៤
ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
ប្រធាន

អ៊ឹម សួស្ដី

ចម្លងជូនថ្វាយ
- ព្រះមហាក្សត្រ

ចម្លងជូន
- ក្រុមប្រឹក្សាធម្មនុញ្ញ
- ព្រឹទ្ធសភា
- រដ្ឋសភា
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- មជ្ឈមណ្ឌលតំកល់ឯកសារជាតិ
- គណបក្សនយោបាយ " ដើម្បីជូនជ្រាប "
- ដូចប្រការ ២ " ដើម្បីអនុវត្ត "
- ឯកសារ-កាលប្បវត្តិ